# ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ
# ក្នុងរបបខ្មែរក្រហម



បោះពុម្ព លើកទី១

# មាតិកា


អារម្ភកថា ........................................................................១

ចំណាប់អារម្មណ៍របស់អង្គភាពគាំពារជនរងគ្រោះ ............២

១. របបកម្ពុជាប្រជាធិបតេយ្យ .....................................៣

២. អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ....៥

២.១ អំពី អ.វ.ត.ក ..................................................៥

២.២ សំណុំរឿងនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)..................................................៦

២.២.១ សំណុំរឿង ០០១ ........................................៧

២.២.២ សំណុំរឿង ០០២ ........................................៨

- សំណុំរឿង ០០២ ដំណាក់កាលទី១....................១១
- សំណុំរឿង ០០២ ដំណាក់កាលទី២....................១២

២.២.៣ សំណុំរឿង ០០៣ & ០០៤............................១៣

៣. អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈក្នុងបរិបទអាពាហ៍ពិពាហ៍ដោយបង្ខំ........................................១៤

៣.១ តើអ្វីជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងរបបខ្មែរក្រហម? ...............................................................១៥




ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញអំឡុង ឆ្នាំ ១៩៧៥
ប្រភពរូបៈ រ៉ូឡែន ណេវ៉ូ (Roland Neveu)




៣.២ ចំនួនដើមបណ្តឹងរដ្ឋប្បវេណី នៃអាពាហ៍ពិពាហ៍ដោយបង្ខំ .............១៩

៣.៣ ការគាំពារផ្នែកច្បាប់ និងផ្លូវចិត្ត.............២០

៤. ទស្សនៈរបស់អ្នកជំនាញ និងសំឡេងជនរងគ្រោះ.............២១

៤.១ ហិង្សាយេនឌ័រក្នុងសម័យខ្មែរក្រហមដោយផ្សាភ្ជាប់នឹងហិង្សាយេនឌ័រ..២២

៤.២ ការគាំពារផ្លូវចិត្ត ដល់ជនរងគ្រោះដោយហិង្សាយេនឌ័រ .............២៣

៤.៣ សំឡេងរបស់ជនរងគ្រោះ និងទស្សនៈនៃការចូលរួមក្នុងដំណើរការក្តីនៅអ.វ.ត.ក .............២៤

៤.៣.១ អ្នកស្រី ជា ឌៀប.............២៨

៤.៣.២ អ្នកស្រី មុំ សុវណ្ណ.............៣២

៤.៣.៣ អ្នកស្រី សំ យ៉ាន.............៣៤

៤.៣.៤ អ្នកស្រី ហែម ពៅ.............៣៥

៤.៣.៥ អ្នកស្រី យ៉ែម រ៉ៃ.............៣៦

៤.៣.៦ លោក យស់ ផល.............៣៨

៤.៣.៧ អ្នកស្រី ប៉ែន សុខចាន់ .............៤០

៤.៣.៨ អ្នកស្រី ស៊ូ សុផារី.............៤២

៥.ព័ត៌មានអំពីអ្នករៀបចំគម្រោង និងអង្គការដៃគូ.............៤៤

៦.អង្គការដែលធ្វើការក្នុងបរិបទហិង្សាយេនឌ័រក្នុងរបបខ្មែរក្រហម.............៤៦

៧. ឯកសារយោង.............៤៧





*រៀបរៀងដោយ៖* អង្គភាពគាំពារជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)

*បោះពុម្ព៖* ខែ សីហា ឆ្នាំ ២០១៧ ភ្នំពេញ កម្ពុជា

*រូបភាពក្របក្រៅ៖* ពិធីរៀបអាពាហ៍ពិពាហ៍របស់ នន់ ហ៊ុយ រហ័សនាម ហ៊ុយ ស្រែ។

*ប្រភពរូប៖* មជ្ឈមណ្ឌលឯកសារកម្ពុជា

ប្រជាជនកម្ពុជា
ត្រូវការចងចាំអតីតកាល
ប៉ុន្តែពួកគាត់ត្រូវការរស់នៅ
ក្នុងបច្ចុប្បន្នកាលប្រកបដោយអត្ថន័យ
និងធ្វើដំណើរដោយមោទនភាពឆ្ពោះទៅ
កាន់អនាគតប្រកបដោយភាពត្រចះត្រចង់។

# អារម្ភកថា



ប្រជាជនកម្ពុជាពី ១,៧ លានទៅ ២,២លាន នាក់បានស្លាប់បាត់បង់ជីវិតក្នុងរបបកម្ពុជាប្រជាធិបតេយ្យនៅចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។ ទោះជារបបនេះបានដួលរលំ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ហើយក្តី ក៏ប្រទេសកម្ពុជានៅតែបន្តទទួលរងគ្រោះដោយសារសង្គ្រាមស៊ីវិលរហូតដល់ចុងទសវត្សរ៍ឆ្នាំ ១៩៩០។ គោលនយោបាយ ឈ្នះ-ឈ្នះ ដាក់ចុះឱ្យអនុវត្តដោយ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន បានធ្វើឱ្យអង្គការចាត់តាំងនយោបាយ និងយោធារបស់ខ្មែរក្រហមត្រូវបានរលំរលាយទាំងស្រុង ហើយកម្ពុជាមានសុខសន្តិភាព ឯកភាពជាតិ និងឯកភាពទឹកដី ព្រមទាំងការអភិវឌ្ឍចាប់តាំងពីចុងឆ្នាំ ១៩៩៨ តរៀងមក។

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដ៏យង់ឃ្នង ប្រជាជនកម្ពុជាទូទាំងប្រទេស បានទទួលរងនូវភាពឈឺចាប់ និងទុក្ខវេទនាគ្រប់បែបយ៉ាង។ ដោយឡែក ស្រ្តីបានទទួលរងគ្រោះពីអំពើហិង្សាផ្លូវភេទ និងយេនឌ័រ ជារួមមាន ការរំលោភសេពសន្ថវៈ ការបង្ខំឱ្យរៀបការ ការបង្ខំឱ្យធ្វើការអំឡុង និងក្រោយពេលសំរាលកូន។ល។ ឧក្រិដ្ឋកម្មទាំងនេះបានបន្សល់ទុកនូវភាពអាម៉ាស់ ការឈឺចាប់ ផ្នែករាងកាយ និងផ្លូវចិត្តដល់ជនរងគ្រោះ ហើយការខិតខំប្រឹងប្រែងក្នុងការផ្តល់យុត្តិធម៌ និងការគាំពារដល់ពួកគាត់កំពុងតែបន្តកើតមានឡើងលើវិស័យផ្សេងៗ ដូចជា ការព្យាបាលផ្លូវចិត្ត ការសិក្សាផ្នែកប្រវត្តិសាស្ត្រ ការរក្សាការចងចាំជាដើម។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ និងបានចាប់ផ្តើមដំណើរការនីតិវិធីរបស់ខ្លួននៅដើមខែកុម្ភៈ ឆ្នាំ ២០០៦ ដើម្បីជំនុំជម្រះក្តីលើមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ប្រព្រឹត្តឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយនេះគឺជាការឆ្លើយតបដ៏សំខាន់មួយទៅនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងរបបនោះ។ អង្គហេតុជាច្រើនត្រូវបាន អ.វ.ត.ក ដាក់បញ្ចូលក្នុងដំណើរការជំនុំជម្រះ ដោយក្នុងនោះក៏មាន អង្គហេតុស្តីពីការរៀបការដោយបង្ខំនិងការរំលោភសេពសន្ថវៈក្នុងបរិបទនៃអាពាហ៍ពិពាហ៍ ដោយបង្ខំ ក្នុងរបបខ្មែរក្រហម ផងដែរ ព្រោះវាជាទង្វើអមនុស្សធម៌មួយ ពាក់ព័ន្ធនឹង បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ បច្ចុប្បន្ននេះ ជនរងគ្រោះពីរបបនោះបានចូលរួម ចែករំលែកនូវរឿងរ៉ាវដ៏ល្វីងជូរចត់របស់ខ្លួនដល់អ្នកជំនាន់ក្រោយ តាមរយៈការផ្តល់សក្ខីកម្ម នៅ អ.វ.ត.ក ការសន្ទនាអន្តរជំនាន់ និងកម្មវិធីផ្សព្វផ្សាយផ្សេងៗ ដូចជាការតាំងពិព័រណ៌ វេទិកាសាធារណៈ និងកម្មវិធីវិទ្យុជាដើម។

ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់រាជរដ្ឋាភិបាលកម្ពុជា ម្ចាស់ជំនួយ អង្គការជាតិ និងអន្តរជាតិ ព្រមទាំងជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានគាំទ្រ និងចូលរួមក្នុងបេសកកម្មរបស់ អ.វ.ត.ក ដើម្បីបុព្វហេតុ ការស្វែងរកការពិត យុត្តិធម៌ និងការរក្សាការចងចាំ ព្រមទាំងរួមគ្នាលុបបំបាត់និទណ្ឌភាពហើយប្រជាជនកម្ពុជាបានសិក្សាពីអតីតកាល រស់នៅក្នុងពេលបច្ចុប្បន្នប្រកបដោយអត្ថន័យ និងធ្វើដំណើរទៅមុខប្រកប ដោយមោទនភាព។

**ក្រាញ់ តូនី**

**ប្រធានការិយាល័យរដ្ឋបាលស្តីទី នៃ អ.វ.ត.ក**



# ចំណាប់អារម្មណ៍របស់អង្គភាពគាំពារជនរងគ្រោះ

អង្គភាពគាំពារជនរងគ្រោះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០៨ សម្រាប់សម្របសម្រួលឱ្យការចូលរួមរបស់ជនរងគ្រោះក្នុងរបបខ្មែរក្រហមក្នុងនីតិវិធីនៃ អ.វ.ត.ក ប្រកបដោយអត្ថន័យ។ ការងារចម្បងៗទាំងនោះរួមមានដូចជា ការសម្របសម្រួលឱ្យជនរងគ្រោះចូលរួមក្នុងសវនាការនៅ អ.វ.ត.ក ការរៀបចំវេទិកា និងកិច្ចពិភាក្សាជាមួយនឹងដើមបណ្ដឹងរដ្ឋប្បវេណី ការកំណត់ ការរៀបចំ និងការអនុវត្តគម្រោងសំណងក្នុងប្រព័ន្ធតុលាការ និងវិធានការនានាក្រៅបច្ចេកទេសតុលាការ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងផ្ដល់ផលប្រយោជន៍ដ៏ទូលំទូលាយដល់ជនរងគ្រោះនៃរបបខ្មែរក្រហមជាទូទៅ។

យើងទាំងអស់គ្នាត្រូវចងចាំថា ប្រទេសកម្ពុជាធ្លាប់ឆ្លងកាត់ទំព័រប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតក្នុងរយៈពេល ៣ឆ្នាំ ៨ខែ ២០ថ្ងៃ ហើយត្រូវទទួលស្គាល់ថា អតីតកាលទាំងនោះមិនអាចកែប្រែបានទេ។ បច្ចុប្បន្ន អ្វីដែលអ្នកនៅរស់រានមានជីវិត និងអ្នកបន្តវេនកម្ពុជា ត្រូវធ្វើនោះ គឺការចូលរួមក្នុងការស្វែងរកការពិត សិក្សាស្វែងយល់ពីអតីតកាល ចងក្រងជាប្រវត្តិសាស្ត្រ និង ដកស្រង់នូវបទពិសោធន៍ទាំងនេះដើម្បីឱ្យប្រាកដថារឿងរ៉ាវដ៏ឃោរឃៅដែលកើតមានឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យនឹងមិនអាចកើតឡើងម្ដងទៀតឡើយ ហើយគ្រប់គ្នាអាចរស់នៅក្នុងសង្គមមួយដែលមានការគោរពសិទ្ធិ សេរីភាព និងមានការអភិវឌ្ឍប្រកបដោយភាពវិជ្ជមាន ។

ការតាំងពិព័រណ៍ចល័តស្ដីពីអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ ក្នុងបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ នឹងបង្ហាញជាសាធារណៈនូវការចាត់ចែង និងការរៀបចំអាពាហ៍ពិពាហ៍ និងគ្រួសារនៅសម័យខ្មែរក្រហម និងការឈឺចាប់ដែលជនរងគ្រោះបានរងទទួលនៅក្នុងរបបនោះ។ ព្រឹត្តិការណ៍នេះ នឹងបង្កើនសំឡេងជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ និងយេនឌ័រដើម្បីឱ្យពួកគាត់ទទួលបានការគាំទ្រពេញលេញក្នុងដំណើរការស្វែងរកយុត្តិធម៌របស់ខ្លួន។ ការចូលរួមរបស់ សិស្ស និស្សិត និងសាធារណជននឹងជំរុញពួកគេឱ្យមានសមាណចិត្តអាណិតអាសូរដល់ជនរងគ្រោះ និងយល់ដឹងអំពីទំនាក់ទំនងនៃអំពើហឹង្សាក្នុងសម័យខ្មែរក្រហម និងសង្គមបច្ចុប្បន្ន និងចេះបង្កើតនូវវប្បធម៌ដំណោះស្រាយដែលមានលក្ខណៈយុត្តិធម៌ និងប្រជាធិបតេយ្យ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ ដើមបណ្ដឹងរដ្ឋប្បវេណី អង្គការដៃគូរ ក្រសួងនិងស្ថាប័ននានា និងជាពិសេសដល់ម្ចាស់ជំនួយ មូលនិធិអង្គការសហប្រជាជាតិដើម្បីលុបបំបាត់អំពើហិង្សាលើស្ត្រី ដែលបានចូលរួម គាំទ្រ និងសហការ ដើម្បីឱ្យគម្រោងនេះទទួលបានជោគជ័យ។

**ហង្ស វណ្ណៈ**

**ប្រធានអង្គភាពគាំពារជនរងគ្រោះ**

# ១. របបកម្ពុជាប្រជាធិបតេយ្យ

របបកម្ពុជាប្រជាធិបតេយ្យ(របបខ្មែរក្រហម)បានឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយត្រូវបានដួលរលំនៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ តែសង្គ្រាមស៊ីវិលបានបន្តក្រោយពីការដួលរលំនៃរបបនេះ។ នៅទីបំផុតសង្គ្រាមស៊ីវិលត្រូវបានបញ្ចប់នៅឆ្នាំ ១៩៩៨ នៅពេលដែលរចនាសម្ព័ន្ធនយោបាយ និងយោធារបស់ខ្មែរក្រហមត្រូវកម្ទេចចោល[១]។ ប្រជាជនចំនួន១,៧ ទៅ ២,២ លាននាក់[២]បានស្លាប់នៅក្រោមរបបខ្មែរក្រហម ដោយការអត់អាហារ អំពើទារុណកម្ម ការសម្លាប់ ការបង្ខំឱ្យធ្វើការលើសកម្លាំង ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ។ល។ ក្រៅពីអំពើមនុស្សឃាត និងការធ្វើទារុណកម្មលើប្រជាជន មេដឹកនាំខ្មែរក្រហមបានធ្វើការផ្លាស់ប្តូរទាំងស្រុងនូវប្រពៃណី និងវប្បធម៌នៃសង្គមកម្ពុជា ដែលបណ្តាលឱ្យប្រជាជនកម្ពុជាចោទសួរពីមធ្យោបាយដែលធ្វើឱ្យពួកគេរួចផុតជីវិតពីរបបនោះ និងពីទំនាក់ទំនងរបស់ពួកគេជាមួយអ្នកដទៃ។បច្ចុប្បន្ននេះប្រជាជនកម្ពុជាកំពុងទទួលរងនូវការលំបាកនានាដែលបន្សល់ទុកពីរបបនេះ។



ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញអំឡុង ឆ្នាំ ១៩៧៥

ប្រភពរូបៈ AFP/Getty Image

[១] https://www.eccc.gov.kh/12278
[២] ដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០២, ទំព័រទី ៤៥១



សម្តេចវិបុលបញ្ញា សុខ អាន ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលកម្ពុជាសម្រាប់កិច្ចសហប្រតិបត្តិការជាមួយអ្នកជំនាញការអន្តរជាតិ ផ្នែកច្បាប់ និងការរៀបចំដំណើរការកាត់ក្តីមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម និងឯកឧត្តម ហាន់ កូរ៉ែល អគ្គលេខាធិការរងសម្រាប់កិច្ចការច្បាប់ ទីប្រឹក្សាច្បាប់ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ នៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣។ ប្រភពរូបៈ អ.វ.ត.ក។

# ២. អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)

## ២.១ អំពីអ.វ.ត.ក

នៅឆ្នាំ ១៩៩៧ រាជរដ្ឋាភិបាលកម្ពុជាបានសំណូមពរឱ្យអង្គការសហប្រជាជាតិជួយក្នុងការបង្កើតសាលាក្តីដើម្បីជំនុំជម្រះទោសមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៧ មេសា ១៩៧៥ ដល់ ៦ មករា ១៩៧៩)។

ច្បាប់ស្តីពីការបង្កើត “អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា” ឬភាគច្រើនហៅថា “សាលាក្តីខ្មែរក្រហម” បានអនុម័តដោយរដ្ឋសភាជាតិកម្ពុជានៅក្នុងឆ្នាំ ២០០១។ កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិត្រូវបានចុះហត្ថលេខានៅនៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣ ដែលចែងអំពីការចូលរួមចំណែករបស់សហគមន៍អន្តរជាតិ និងរបៀបនៃការសហការនៅក្នុងដំណើរការអង្គជំនុំជម្រះវិសាមញ្ញនេះ។

បើទោះបីជាតុលាការពិសេសមួយនេះ ត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិក៏ពិតមែន តែតុលាការនេះជាតុលាការឯករាជ្យ និងមិនចំណុះឱ្យរាជរដ្ឋាភិបាល ឬអង្គការសហប្រជាជាតិឡើយ ហើយដំណើរការនីតិវិធីរបស់ខ្លួនតាមបទដ្ឋានអន្តរជាតិដោយអនុវត្តច្បាប់ជាតិ និងអន្តរជាតិ[៣]។

[៣] https://www.eccc.gov.kh/en/about-eccc/introduction (ECCC at a glance)



សាលសវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ប្រភពរូប៖ អ.វ.ត.ក

## ២.២ សំណុំរឿងនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា



ការចូលរួមរបស់សាធារណជនក្នុងសំណុំរឿង ០០២ នៅ អ.វ.ត.ក
ប្រភពរូប៖ អ.វ.ត.ក



**ទណ្ឌិត កាំង ហ្គេកអ៊ាវ (ហៅឌុច)**
ប្រភពរូប៖ អ.វ.ត.ក

## ២.២.១ សំណុំរឿង ០០១

សាលាក្ដីខ្មែរក្រហមបានបិទបញ្ចប់សំណុំរឿង ០០១ ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនៅគុកទួលស្លែង ដែលមាន ទណ្ឌិត កាំង ហ្គេកអ៊ាវ (ហៅឌុច) ជាអ្នកទទួលខុសត្រូវ។

នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ កាំង ហ្គេកអ៊ាវ ត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតដោយអង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបទបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩[៤]។ បច្ចុប្បន្នឌុចកំពុងអនុវត្តទោសរបស់ខ្លួននៅពន្ធនាគារខេត្តកណ្ដាល[៥]។

[៤] https://www.eccc.gov.kh/case/topic/90
[៥] https://www.eccc.gov.kh/articles/26520



អៀង ធីរិទ្ធ
អតីតរដ្ឋមន្ត្រីសង្គមកិច្ច



អៀង សារី អតីតឧបនាយករដ្ឋមន្ត្រី
ទទួលបន្ទុកការបរទេស
នៃរបបកម្ពុជាប្រជាធិបតេយ្យ

ប្រភពរូប៖ អ.វ.ត.ក



## ២.២.២ សំណុំរឿង ០០២

» សំណុំរឿង ០០២ មានជនជាប់ចោទចំនួន ៤ រូប គឺ៖ ១) នួន ជា អតីតប្រធានសភាប្រជាជន នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា ២) ខៀវ សំផន អតីតប្រមុខរដ្ឋ (ប្រធានគណៈប្រធានរដ្ឋ) នៃរបបកម្ពុជាប្រជាធិបតេយ្យ ៣) អៀង សារី ជាអតីតឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ និង ៤) អៀង ធីរិទ្ធ ជាអតីតរដ្ឋមន្ត្រីក្រសួងសង្គមកិច្ចនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

» អៀង សារី បានស្លាប់កាលពីថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត និង អៀង ធីរិទ្ធ បានស្លាប់កាលពីថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៥ នៅខេត្តប៉ៃលិន។ បទចោទប្រកាន់នឹងពួកគាត់ទាំងពីរខាងលើនេះត្រូវបានលុបចោល។

» បច្ចុប្បន្ននេះមានតែ នួន ជា និងខៀវ សំផន ប៉ុណ្ណោះដែលកំពុងស្ថិតនៅក្នុងដំណាក់កាលជំនុំជម្រះនៃសំណុំរឿង ០០២ ដំណាក់កាលទី២។



នួន ជា
អតីតប្រធានសភាប្រជាជននៃ
របបកម្ពុជាប្រជាធិបតេយ្យ



ខៀវ សំផន អតីតប្រមុខរដ្ឋ
(ប្រធានគណៈប្រធានរដ្ឋ)
នៃរបបកម្ពុជាប្រជាធិបតេយ្យ

ប្រភពរូបៈ អ.វ.ត.ក

នួន ជា (ឈ្មោះកំណើត ឡៅ គឹមលន) កើតនៅក្នុងឆ្នាំ១៩២៦ ក្នុងភូមិវត្តគរ ខេត្តបាត់ដំបង។

នួន ជា (ភាគច្រើនគេស្គាល់ថា បងធំទីពីរ) ជាអតីតប្រធានសភាប្រជាជន នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា។

នៅសម័យខ្មែរក្រហម នួន ជា មានភារៈសម្រេចច្បាប់ និងកំណត់មាគ៌ានយោបាយផ្សេងៗក្នុងប្រទេស និងក្រៅប្រទេសរបស់កម្ពុជាប្រជាធិបតេយ្យ[៦] និងទទួលខុសត្រូវក្នុងការឃោសនា បណ្តុះបណ្តាល បញ្ហាវិន័យរបស់កម្មាភិបាល ព្រមទាំងបញ្ហាដែលទាក់ទងនឹងសន្តិសុខខាងក្នុង និងខាងក្រៅ[៧]។

ខៀវ សំផន កើតក្នុងឆ្នាំ ១៩៣១ ក្នុងខេត្តស្វាយរៀង។ តួនាទីរបស់ ខៀវ សំផន មានដូចជាៈ

» ប្រមុខរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យដែលមាន ភារៈតំណាងឱ្យរដ្ឋកម្ពុជាប្រជាធិបតេយ្យនៅក្នុងប្រទេស និងក្រៅប្រទេស។
» ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការពារជាតិ និងអគ្គមេបញ្ជាការ

[៦] រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)
[៧] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងប្រកាសនៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ សំណុំរឿងលេខ០០២/០១ ទំព័រទី ២៥០

កងទ័ពរំដោះជាតិកម្ពុជា (ក្នុងដំណាក់កាលដំបូងនៃរបបខ្មែរក្រហម)។

» សមាជិកថ្នាក់ដឹកនាំម្នាក់នៃមន្ទីរ ៨៧០ មានការទទួលខុសត្រូវផ្នែកពាណិកម្ម និងជាសមាជិកគណៈកម្មាធិការមជ្ឈឹមបក្សកុម្មុយនីស្តកម្ពុជា[៨]។
» ឆ្នាំ ១៩៨៧ គាត់បានជំនួសតំណែង ប៉ុល ពត ជាក្បាលម៉ាស៊ីនដឹកនាំរបស់ក្រុមខ្មែរក្រហម។
» ឆ្នាំ ១៩៨៩ គាត់បានធ្វើជាតំណាងកម្ពុជាក្នុងសន្និសីទអន្តរជាតិស្តីពីកម្ពុជានៅទីក្រុងប៉ារីស។
» ខៀវ សំផន ត្រូវបានចាប់និងឃុំខ្លួននៅ អ.វ.ត.ក នៅខែវិច្ឆិកា ឆ្នាំ២០០៧។

## ព័ត៌មានអំពីបច្ចុប្បន្នភាពនៃសំណុំរឿង ០០២

នួន ជា និងខៀវ សំផន ត្រូវបានចោទប្រកាន់ថាមានការទទួលខុសត្រូវតាមរយៈការធ្វើសកម្មភាព ឬបរាជ័យក្នុងការទប់ស្កាត់ (រួមបញ្ចូលទាំងការប្រព្រឹត្តតាមរយៈឧស្សាហកម្ម ឧក្រិដ្ឋកម្មរួម) បញ្ជា ញុះញង់ រៀបចំផែនការ ដឹកនាំ ឬសមគំនិតដោយការជួយឬជំរុញ ឬបង្កលក្ខណៈងាយស្រួលដល់ការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬទទួលខុសត្រូវក្នុងនាមជាអ្នកដឹកនាំ ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនៅចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

អង្គជំនុំជម្រះសាលាដំបូង បានបើកសវនាការបឋមនៅខែមិថុនា ឆ្នាំ ២០១១។ ចាប់ពីពេលនោះមក សំណុំរឿង ០០២ បានបំបែកយ៉ាងហោចណាស់ជាពីរដំណាក់កាលគឺ ០០២ ដំណាក់កាលទី១ និង០០២ ដំណាក់កាលទី២ ដែលសវនាការនីមួយៗដោះស្រាយផ្នែកផ្សេងគ្នានៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[៨] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងប្រកាសនៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ សំណុំរឿងលេខ០០២/០១ ទំព័រទី ៣០៧

## សំណុំរឿង ០០២ ដំណាក់កាលទី១៖

ការជំនុំជម្រះដំណាក់កាលទីមួយ (សំណុំរឿង ០០២/០១) ត្រូវបានចាប់ផ្ដើមនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១ ដោយផ្ដោតជាចម្បងទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ និងក្រោយមកទៀត ចេញពីតំបន់ផ្សេងៗ (ដំណាក់កាល ទីមួយ និងទីពីរ) និងការសម្លាប់ទាហាន លន់ នល់ នៅទីតាំងសម្លាប់មនុស្សទួលពោធិ៍ជ្រៃបន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាចភ្លាមៗក្នុងឆ្នាំ ១៩៧៥។ សវនាការលើភស្តុតាងក្នុងសំណុំរឿង ០០២ ដំណាក់កាលទី១ ត្រូវបានបញ្ចប់នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣ ដែលមានរយៈពេលសរុប ២២២ថ្ងៃ ក្នុងនោះអង្គជំនុំជម្រះសាលាដំបូងបានស្ដាប់សក្ខីកម្មរបស់បុគ្គលចំនួន ៩២រូប ដែលរួមមានអ្នកជំនាញ ៣ រូប សាក្សីអង្គហេតុចំនួន ៥៣រូប សាក្សីបញ្ជាក់ពីអត្តចរិតជនជាប់ចោទ ៥រូប និងដើមបណ្ដឹងរដ្ឋប្បវេណីចំនួន៣១ រូប[៩]។ នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូង បានផ្ដន្ទាទោសឱ្យ នួន ជា និងខៀវ សំផនជាប់ពន្ធនាគារអស់មួយជីវិតពីបទចោទប្រកាន់ខាងលើ។

នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានប្រកាសសាលដីកាលើបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង ០០២/០១ ដោយតម្កល់ទោសជាប់ពន្ធនាគារអស់មួយជីវិតដល់ នួន ជា និងខៀវ សំផន ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំក្នុងដំណាក់កាលទីមួយ និងទីពីរ ប៉ុន្តែបានបដិសេធថា ទណ្ឌិតទាំងពីរ ពុំមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះការកាប់សម្លាប់នៅទួលពោធិ៍ជ្រៃទេ[១០]។ មានគម្រោងសំណង ១១ ត្រូវបានទទួលស្គាល់ដោយតុលាការ និងបានអនុវត្តទូទាំងប្រទេស[១១]។

[៩] https://www.eccc.gov.kh/articles/27938
[១០] https://www.eccc.gov.kh/articles/39043
[១១] https://www.eccc.gov.kh/articles/30544

## សំណុំរឿង ០០២ ដំណាក់កាលទី២៖

នៅក្នុងសេចក្តីសម្រេចមួយកាលពីថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថាទីតាំងឧក្រិដ្ឋកម្ម និងការចោទប្រកាន់ផ្នែកអង្គហេតុខាងក្រោមនេះនឹងបង្កើតបានជាមូលដ្ឋានសម្រាប់សំណុំរឿង០០២/០២៖ អំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិចាម និងជនជាតិវៀតណាម (ដោយមិនរាប់បញ្ចូលនូវឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលប្រព្រឹត្តឡើងដោយកងទ័ពបដិវត្តន៍កម្ពុជានៅលើដែនដីវៀតណាមនោះឡើយ) ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ (នៅទូទាំងប្រទេស) ការបោសសម្អាតផ្ទៃក្នុង មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រោល ការដ្ឋានសាងសង់ទំនប់១មករា ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង និងការដ្ឋានលើកទំនប់ត្រពាំងថ្ម សហករណ៍ត្រាំកក់ ការប្រព្រឹត្តមកលើពុទ្ធសាសនិកជន (កម្រិតត្រឹមតែសហករណ៍ត្រាំកក់) និងការធ្វើទុក្ខបុកម្នេញដល់ក្រុមមុខសញ្ញាដែលជាអតីតមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរ (ការអនុវត្តនេះត្រូវបានកម្រិតត្រឹមតែសហករណ៍ត្រាំកក់ ការដ្ឋានសាងសង់ទំនប់១មករា មន្ទីរសន្តិសុខ ស-២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់)[១២]។

អង្គជំនុំជម្រះបានធ្វើសវនាការអស់រយៈពេល ២៧៤ថ្ងៃ ចាប់ពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ និងបញ្ចប់នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧។ មានសាក្សីចំនួន ១១៤ នាក់ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន៦៣នាក់ និងអ្នកជំនាញចំនួន៨នាក់ បានផ្តល់សក្ខីកម្ម[១៣]។ បច្ចុប្បន្នសំណុំរឿង០០២ ដំណាក់កាលទីពីរ កំពុងស្ថិតក្នុងដំណាក់កាលការពិភាក្សាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង។



មាស មុត



អោ អាន

[១២] https://www.eccc.gov.kh/case/topic/119

[១៣] https://www.eccc.gov.kh/articles/39455



អ៊ឹម ចែម



យឹម ទិត្យ

## ២.២.៣ សំណុំរឿង ០០៣ និង ០០៤

» **សំណុំរឿង ០០៣៖** មានជនជាប់ចោទ មាស មុត និងអតីតសហជនសង្ស័យ ស៊ូ ម៉េត។

- **មាស មុត៖** កិច្ចស៊ើបសួររបស់តុលាការពាក់ព័ន្ធនឹងរូបគាត់ ត្រូវបានបិទបញ្ចប់ថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧។
- **ស៊ូ ម៉េត៖** កិច្ចស៊ើបសួរពាក់ព័ន្ធនឹងអតីតសហជនសង្ស័យរូបនេះ ត្រូវបានលុបចោល ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៥ បន្ទាប់ពីគាត់បានស្លាប់ទៅ[១៤]។

» **សំណុំរឿង ០០៤៖** មានជនជាប់ចោទ ១) អ៊ឹម ចែម ២) អោ អាន  និង ៣) យឹម ទិត្យ។

- **អ៊ឹម ចែម៖** សំណុំរឿងរបស់គាត់ត្រូវបានបំបែកទៅជាសំណុំរឿង ០០៤/០១[១៥]។ ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ ២០១៥ កិច្ចស៊ើបសួរពាក់ព័ន្ធនឹងរូបគាត់ត្រូវបានបញ្ចប់។ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧ គាត់ត្រូវបានលើកលែងការចោទប្រកាន់ដោយសហចៅក្រមស៊ើបអង្កេត[១៦]។
- **អោ អាន៖** សំណុំរឿងរបស់គាត់ត្រូវបានបំបែក ទៅជាសំណុំរឿង ០០៤/០២[១៧]។ កិច្ចស៊ើបសួរពាក់ព័ន្ធនឹងរូបគាត់ត្រូវបានបិទបញ្ចប់កាលពីថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦។ នៅថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតបានចេញដីកាបញ្ជូន សំណុំរឿងអនុលោមតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង ដោយបានស្នើសុំឱ្យសហព្រះរាជអាជ្ញាដាក់សេចក្ដីសន្និដ្ឋានស្ថាពររបស់ខ្លួន[១៨]។
- **យឹម ទិត្យ៖** កិច្ចស៊ើបសួរពាក់ព័ន្ធនឹងរូបគាត់ត្រូវបានបិទបញ្ចប់ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧[១៩]។

[១៤] https://www.eccc.gov.kh/articles/39445
[១៥] https://www.eccc.gov.kh/articles/36611
[១៦] https://www.eccc.gov.kh/articles/39515
[១៧] https://www.eccc.gov.kh/articles/39325
[១៨] https://www.eccc.gov.kh/articles/39615
[១៩] https://eccc.gov.kh/node/39671

ប្រភពរូប៖ អ.វ.ត.ក

# ៣. អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈក្នុងបរិបទអាពាហ៍ពិពាហ៍ដោយបង្ខំ

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានអនុវត្តទូទាំងប្រទេសតាមរយៈមធ្យោបាយចាំបាច់នានា ចាប់ពីមុនឆ្នាំ១៩៧៥ រហូតដល់យ៉ាងហោចណាស់ ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។ យោងតាមការចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតនៅទូទាំងប្រទេសកម្ពុជា បុរសនិង ស្ត្រី ត្រូវបានគេបង្ខំឱ្យរៀបការនៅក្នុងពិធីរួមគ្នាដែលមានចាប់ពី ០២ ទៅជាង ១០០ គូក្នុងមួយលើកៗ។ គោលបំណងនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនេះគឺដើម្បីៈ

- គ្រប់គ្រងទំនាក់ទំនងរវាងបុគ្គល ដូច្នេះពួកគេបានត្រឹមតែត្រូវបានអនុញ្ញាតឱ្យរៀបការ និងមានទំនាក់ទំនងផ្លូវភេទ។
- ទស្សនៈនៃការរៀបអាពាហ៍ពិពាហ៍ត្រូវបានស្ថាបនាឡើងវិញនៅក្រោមរបបបក្សកុម្មុយនីស្តកម្ពុជាដើម្បីឱ្យបក្សកុម្មុយនីស្តនេះអាចជំនួសតួនាទីរបស់ឪពុក ម្តាយ និងដើម្បីឱ្យម្តាយអាចទៅធ្វើការបានដូចធម្មតា។
- បង្កើនកំណើនប្រជាជននិងកសាងក្រុមគ្រួសារ។

ប៉ុល ពត បានថ្លែងថា “បុរសវ័យក្មេង និងស្ត្រីវ័យក្មេងត្រូវកសាងក្រុមគ្រួសារដោយផ្អែកលើមូលដ្ឋានស្ម័គ្រចិត្ត” ហើយការរៀបអាពាហ៍ពិពាហ៍ត្រូវផ្អែកលើសំណើរបស់បុគ្គលណាម្នាក់ដើម្បីស្វែងរកគូស្រករ និងយោងតាមសេចក្តីសម្រេចរបស់គណៈកម្មាធិការបញ្ជា។ សាក្សីជាច្រើន បាននិយាយថាពួកគេត្រូវបានបង្ខំឱ្យរៀបការ។ ទោះបីជាមន្ត្រីដែលបានបញ្ជាក់ថាបុគ្គលម្នាក់ៗបានយល់ព្រមដោយសេរីឱ្យមានការរៀបការ ក៏មន្ត្រីទាំងនោះបានកត់សម្គាល់ថា នៅក្នុងការអនុវត្តជាក់ស្តែងប្រជាជនមិនអាចប្រឆាំងបានទេពីព្រោះពួកគេភ័យខ្លាច ទទួលរងនូវអំពើហិង្សាឬការកាប់សម្លាប់[២០]។

[២០] https://www.eccc.gov.kh/node/38384

## ៣.១ តើអ្វីជាអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងរបបខ្មែរក្រហម?

ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំគឺ ជាប្រភេទនៃអំពើហិង្សាផ្លូវភេទ និងយេនឌ័រ ដែលត្រូវបានអនុវត្តក្នុងរបបខ្មែរក្រហម។ បុរស និងស្ត្រីត្រូវបានគេបង្ខំឱ្យរៀបការតាមទំនើងចិត្តដោយគ្មានជម្រើស ឬការព្រមព្រៀង ហើយពួកគេត្រូវបានបង្ខំឱ្យរួមដំណេក។

នៅក្នុងរបបខ្មែរក្រហម ការរៀបអាពាហ៍ពិពាហ៍ទាំងនេះត្រូវប្រារព្ធធ្វើឡើងក្នុងពិធីជាសមូហភាព និងរៀបចំឡើងដោយកម្មាភិបាលខ្មែរក្រហម ដោយធ្វើនៅកន្លែងណាមួយ។ អ្នកត្រូវរៀបការត្រូវបានគេផ្តល់ដំណឹងមុនពេលរៀបការបន្តិចតែប៉ុណ្ណោះ។ ករណីលើកលែងកម្រនឹងមានណាស់ លុះត្រាតែពាក់ព័ន្ធនឹងកម្មាភិបាលខ្មែរក្រហមដែលក្នុងនោះបុរសត្រូវបានអនុញ្ញាតឱ្យជ្រើសរើសអ្នកដែលនឹងក្លាយជាប្រពន្ធរបស់ខ្លួនបាន ប៉ុន្តែបុរស និងស្ត្រីភាគច្រើន មិនមានជម្រើសក្នុងការជ្រើសគូស្រករឡើយ ហើយគូជាច្រើនមិនដែលបានជួបដៃគូអនាគតរបស់ខ្លួនពីមុននោះទេ។ ជាញឹកញាប់អ្នកដែលប្រកែក គឺត្រូវបានចាប់ដាក់គុក រងទារុណកម្ម យកទៅកសាង ឬសម្លាប់ចោល[២១]។

[២១] http://gbvkr.org/kh/gender-based-violence-under-khmer-rouge/facts-and-figures/forced-marriage/



រូបភាព៖ ប៉ុល ពត ថ្លែងសុន្ទរកថានៅក្នុងកិច្ចប្រជុំបក្សអំឡុងឆ្នាំ ១៩៧៥ ប្រភពរូប៖ Ben Kierman

## ការថ្លែងសុន្ទរកថារបស់ ប៉ុល ពត ក្នុងកិច្ចប្រជុំបក្សអំឡុងឆ្នាំ១៩៧៧

*“....សព្វថ្ងៃប្រទេសយើងជាប្រទេសតូច មានប្រជាជនតិច ចំនួនប្រជាជនយើងជិត ៨ លាននាក់ នៅឆ្ងាយណាស់ពីលទ្ធភាពរបស់ប្រទេសយើង ដែលត្រូវការមានជនកម្ពុជាជាង២០លាននាក់ ក្នុងអំឡុងពេលជាង១០ឆ្នាំខាងមុខនេះ... យើងគ្មានហេតុផលអ្វីធ្វើឱ្យចំនួនប្រជាជនយើងថយចុះ ឬនៅដដែលទេ ដូច្នេះទិសដៅរបស់យើងគឺបង្កើតចំនួនប្រជាជនឱ្យបានឆាប់រហ័សបំផុត”*

*ជយោបក្សកុម្មុយនីស្តកម្ពុជាដ៏ត្រឹមត្រូវ និងភ្លឺស្វាងមហាអស្ចារ្យ! ជយោ! ជយោ! ជយោ!*

ឯកសារជាសំឡេងរបស់បក្សកុម្មុនីស្តកម្ពុជា

ប្រភព៖ មជ្ឈមណ្ឌលធនធានសោតទស្សន៍បុប្ផាណា



ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំជាក្រុមក្នុងរបបខ្មែរក្រហម ប្រភពរូបៈ មជ្ឈមណ្ឌលឯកសារកម្ពុជា

# ៣.២ ចំនួនដើមបណ្ដឹងរដ្ឋប្បវេណីនៃអាពាហ៍ពិពាហ៍ដោយបង្ខំនៅ អ.វ.ត.ក




បច្ចុប្បន្នមានដើមបណ្ដឹងរដ្ឋប្បវេណីនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនិងរំលោភសេពសន្ថវៈក្នុងបរិបទអាពាហ៍ពិពាហ៍ដោយបង្ខំចំនួន ៧៧៩នាក់ស្ថិតក្នុងចំណោមដើមបណ្ដឹងរដ្ឋប្បវេណីសរុបទាំងអស់ ៣៨៦៧នាក់ដែលតុលាការបានទទួលស្គាល់ក្នុងសំណុំរឿង ០០២។

*ដើមបណ្ដឹងរដ្ឋប្បវេណីនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ សរុប៧៧៩នាក់ (ស្ត្រី ៥៣៣ បុរស ២៤៦)*




វេទិកាដើមបណ្ដឹងរដ្ឋប្បវេណីដែលរៀបចំដោយអង្គភាពគាំពារជនរងគ្រោះកាលពីឆ្នាំ ២០១៦ នៅខេត្តព្រះសីហនុ

ប្រភពរូបៈ អង្គភាពគាំពារជនរងគ្រោះ

## ៣.៣ ការគាំពារផ្នែកច្បាប់ និងផ្លូវចិត្ត

ជនរងគ្រោះក្នុងរបបខ្មែរក្រហមអាចចូលរួមដោយផ្ទាល់ក្នុងដំណើរការនីតិវិធីរបស់ អ.វ.ត.ក ក្នុងនាមជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿងដែលកំពុងដំណើរការនៅតុលាការ។ ដើម្បីគាំទ្រជនរងគ្រោះឱ្យចូលរួមប្រកប ដោយអត្ថន័យក្នុងដំណើរការនីតិវិធី នៅអ.វ.ត.ក ក្នុងនាមជាដើមបណ្ដឹងរដ្ឋប្បវេណី អង្គភាពគាំពារជនរងគ្រោះ បាន និងកំពុងអនុវត្តនូវសកម្មភាពមួយចំនួនដូចជាៈ

### ការគាំពារផ្នែកច្បាប់

សម្របសម្រួល និងរៀបចំជំនួយផ្នែកច្បាប់ តាមរយៈមេធាវីដល់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងដំណាក់កាលនៃដំណើរការនៃនីតិវិធីរបស់ អ.វ.ត.ក និង រៀបចំកិច្ចប្រជុំ និងសិក្ខាសាលានានាដើម្បីឱ្យជនរងគ្រោះបានសិក្សាស្វែងយល់អំពីការវិវឌ្ឍថ្មីៗរបស់តុលាការ និងជួបពិភាក្សាជាមួយមេធាវីរបស់ខ្លួន និងមន្ត្រីដែលពាក់ព័ន្ធ។ ចាប់ពីដំណាក់កាលជំនុំជម្រះរហូតទៅ ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ក្លាយជាក្រុមតែមួយ ហើយផលប្រយោជន៍របស់ពួកគាត់ត្រូវបានតំណាងដោយសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។

### ការគាំទ្រផ្នែកផ្លូវចិត្ត

ផ្ដល់ការគាំទ្រ និងសេវាផ្លូវចិត្តដល់ដើមបណ្ដឹងរដ្ឋប្បវេណីនៅអំឡុង និងក្រោយពេលពួកគាត់ចូលរួមក្នុងដំណើរការនីតិវិធីរបស់ អ.វ.ត.ក។ ធ្វើការផ្សព្វផ្សាយ និងបណ្ដុះបណ្ដាល អប់រំ អំពីសុខភាពផ្លូវចិត្តទៅសហគមន៍ អង្គការដៃគូពាក់ព័ន្ធ។ សកម្មភាពទាំងនេះបាន និងកំពុងអនុវត្តដោយសហការជាមួយអង្គការដៃគូ ធីភីអូ។

# ៤. ទស្សនៈរបស់អ្នកជំនាញ និងសំឡេងជនរងគ្រោះ










## ៤.១ ហិង្សាយេនឌ័រក្នុងរបបខ្មែរក្រហមដោយផ្សាភ្ជាប់នឹងហិង្សាយេនឌ័រក្នុងសម័យបច្ចុប្បន្ន

*ដោយលោកស្រី កាស៊ូមី ណាកាហ្គាវ៉ា សាស្ត្រាចារ្យវង់សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*



ចាប់តាំងពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ឬ របបខ្មែរក្រហមការខិតខំប្រឹងប្រែងដើម្បីស្វែងរកយុត្តិធម៌សម្រាប់អ្នករស់រានមានជីវិតពីហិង្សាផ្លូវភេទ និងហិង្សាយេនឌ័រ (GBV) នៅមានកម្រិតនៅឡើយ។ វាជាការសំខាន់ណាស់ក្នុងការបំបាត់វប្បធម៌នៃភាពស្ងៀមស្ងាត់ និងនិទណ្ឌភាពព្រមទាំងជួយអ្នកនៅរស់រានមានជីវិតទាំងនោះនៅក្នុងដំណើរការនៃការព្យាបាល និងការស្វែងរកយុត្តិធម៌ទាំងឡាយ។ បទល្មើសប្រឆាំងនឹងស្ត្រីដែលត្រូវបានគេចងក្រងរួមមាន: ការរំលោភសេពសន្ថវៈ ការរំលោភផ្លូវភេទ ការកាត់ប្រដាប់ភេទ ការបង្ខំឱ្យអាក្រាតកាយ និងការបង្ខំឱ្យធ្វើទាសករផ្លូវភេទ។ ចំណែកឯបទល្មើសប្រឆាំងនឹងបុរសដែលត្រូវបានគេចងក្រងជាឯកសាររួមមាន: ការរំលោភសេពសន្ថវៈ និងការរំលោភផ្លូវភេទ។ ការរៀបការដោយបង្ខំជាប្រភេទបទល្មើសដែលមានលក្ខណៈប្លែក និងមានគោលដៅទាំងស្ត្រី និងបុរស ប៉ុន្តែជាទូទៅបុរសមានសេរីភាពច្រើនក្នុងការជ្រើសរើសគូអនាគតរបស់ខ្លួន សូម្បីតែនៅ ពេលដែលពួកគេត្រូវបានបង្ខំឱ្យរៀបការក៏ដោយ។ អំពើហិង្សាផ្លូវភេទដែលស្ថិតនៅក្នុងបរិបទការរៀបអាពាហ៍ពិពាហ៍ គឺជារឿងធម្មតានិងមានការរីករាលដាល។

ប្រជាជននៅក្នុងប្រទេសភាគច្រើនគិតថា វាមិនមែនជាការល្អទេដែលមនុស្សវ័យក្មេងនិយាយដោយបើកចំហរអំពីបញ្ហាផ្លូវភេទដូចជាការរំលោភសេពសន្ថវៈជាដើម។ ផ្ទុយទៅវិញវាជាការសំខាន់ខ្លាំងណាស់ក្នុងការនិយាយអំពីវា ទោះបីជាវាកើតឡើងនៅក្នុងអតីតកាលក៏ដោយពីព្រោះថាបទល្មើសពីអតីតកាលទាំងនោះមានទំនាក់ទំនងទៅនឹងបទល្មើសនៅពេលបច្ចុប្បន្ននេះ។ អំពើហិង្សាលើស្ត្រីគឺជាការបង្ហាញឱ្យឃើញពីការគ្រប់គ្រងដែលយកបុរសជាធំ និងពីភាពខ្ពង់ខ្ពស់របស់បុរស និងជាការបន្តនៃវិសមភាពយេនឌ័រពីអតីតកាល។ តាមរយៈការសិក្សាពីហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហម ក្មេងជំនាន់ក្រោយអាចសិក្សាអំពីការរងទុក្ខវេទនា របស់មាតាបិតានិងជីដូនជីតារបស់ពួកគេ ការតស៊ូ និងក្តីសង្ឃឹមអំឡុងពេលនោះ។ ក្មេងជំនាន់ក្រោយមានកាតព្វកិច្ចដែលមិនអាចប្រកែកបានក្នុងការដឹង ការទទួលស្គាល់ និងយល់ពីអតីតកាលរបស់ប្រទេសខ្លួន ដើម្បីក្លាយជាអ្នកផ្សះផ្សា និងអ្នកការពារប្រទេសជាតិ។

## ៤.២ ការគាំពារផ្លូវចិត្តដល់ជនរងគ្រោះដោយហិង្សាយេនឌ័រ

*ដោយលោកវេជ្ជបណ្ឌិត ឈឹម សុធារ៉ា នាយកប្រតិបត្តិនៃអង្គការចិត្តសង្គមអន្តរវប្បធម៌កម្ពុជា*



អង្គការចិត្តសង្គមអន្តរវប្បធម៌កម្ពុជាហៅកាត់ថា ធីភីអូ ជាអង្គការមួយផ្តោតចម្បងលើការពង្រឹងផ្នែកសុខភាពផ្លូវចិត្ត ហើយអង្គការនេះបាន និងកំពុងធ្វើការយ៉ាងជិតស្និទជាមួយសាលាក្តីខ្មែរក្រហម ចាប់តាំងពីពេលសវនាការចាប់ផ្តើមមកម្ល៉េះ ដើម្បីធ្វើការគាំទ្រផ្លូវចិត្តដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលចូលរួមយ៉ាងសកម្មក្នុងដំណើរការកាត់ក្តី និងធ្វើការផ្សព្វផ្សាយអំពីផលប៉ះពាល់នៃវិបត្តិផ្លូវចិត្តដល់សហគមន៍ជាច្រើននៅក្នុងប្រទេសកម្ពុជា។

ប្រជាជនកម្ពុជានៅតែទទួលរងផលប៉ះពាល់ពីសម័យខ្មែរក្រហម។ អ្នករស់រានមានជីវិតរាប់រយពាន់នាក់បានឆ្លងកាត់ការលំបាក ជាច្រើនដូចជាទារុណកម្ម ការព្រាត់ប្រាស់ពីសាច់ញាតិ កង្វះម្ហូបអាហារ ការបង្ខំឱ្យធ្វើការហួសកំលាំង ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ ។ល។ មនុស្សជាច្រើនយល់ថាប្រជាជនកម្ពុជាមានសភាពធម្មតា និងមិនមានការប៉ះទង្គិចផ្លូវ ចិត្តធ្ងន់ធ្ងរនោះទេ ដោយសារតែឃើញអ្នកទាំងនោះនៅញញឹម ហើយមើលទៅហាក់ដូចជារីករាយនឹងជីវិតប្រចាំថ្ងៃរបស់ពួកគេ ប៉ុន្តែនេះមិនមែនជារឿងពិតទេ។

ភាពឈឺចាប់ទាំងនោះគឺបង្កប់នៅខាងក្នុងខ្លួនអ្នកទាំងនោះ។ បញ្ហាជាច្រើននៅមិនទាន់ទៅណាឆ្ងាយទេ ហើយវាត្រលប់មកវិញពេលណាមានរំញោចណាមួយកើតឡើង ឧទាហរណ៍ដូចជាក្នុងអំឡុងពេលសវនាការនៅសាលាក្តីខ្មែរក្រហម។

តុលាការអាចផ្តល់យុត្តិធម៌ពិតប្រាកដមែន ប៉ុន្តែការផ្តល់ការព្យាបាលផ្លូវចិត្តពីអ្នកជំនាញ វាគឺជាការចាំបាច់ណាស់។ យើងនៅ មានការងារជាច្រើនទៀតដែលត្រូវបន្តធ្វើដើម្បីជួយដល់អ្នករស់រានមានជីវិត ឱ្យអាចឈានទៅរកការជាសះស្បើយខាងផ្លូវចិត្ត ពិតប្រាកដបាន។ វាជាដំណើរព្យាបាលដែលចាំបាច់ត្រូវតែបន្តធ្វើ ហើយជាការងារមួយគ្មានដែនកំណត់ដើម្បីបន្តដោះស្រាយ ជាមួយនឹងវិបត្តិដែលបន្សល់ពីអំពើប្រល័យពូជសាសន៍។ វាមិនហួសពេលនោះទេ ហើយយើងក៏នៅតែអាចទទួលជោគជ័យបានផងដែរ។

# ៤.៣ សំឡេង និងទស្សនៈរបស់ជនរងគ្រោះ



ការចូលរួមប្រជុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណីជាស្ត្រី និងជនរងគ្រោះដោយហិង្សាយេនឌ័រ ជាមួយនឹងមេធាវី ដែលរៀបចំដោយ អង្គភាពគាំពារជនរងគ្រោះនៃ អ.វ.ត.ក ប្រភពរូប៖ អ.វ.ត.ក


UNITED NATIONS
E.C.C.C * C.E.T.C



ខៀវ សំផន ពេលបើកសន្និបាតមួយក្នុងវិហារវត្តឧណ្ណាលោម នៅក្រុងភ្នំពេញ ឆ្នាំ ១៩៧៨ ដោយមានប្រជាជនប្រុសស្រីរាប់រយចូលរួមក្នុងនោះមានប្រជាជនមកពីផ្សារអូឬស្សី ផ្សារចាស់ និងជនជាតិភាគតិចផងដែរ។

ដកស្រង់៖ ប្រវត្តិផ្ទាល់មាត់របស់អ្នកស្រី ជា ឌៀប

គូរដោយ៖ លោក ឱក ប៊ុណ្ណារ័ត្ន

*ខៀវ សំផន៖*

*“...ទាំងយុវជន និងយុវនារី ដែលមានអាយុចាប់ពី ២៥- ៣០ ឆ្នាំត្រូវរៀបការ ដើម្បីធ្វើការងារជូនបដិវត្តន៍ ពង្រឹងជំហរ កុំក្បត់នឹងបក្ស...”*

ដកស្រង់៖ ប្រវត្តិផ្ទាល់មាត់របស់អ្នកស្រី ជា ឡៀប

ដើមបណ្តឹងរដ្ឋប្បវេណី ខេត្តកំពង់ចាម



## ៤.៣.១ អ្នកស្រី ជា ឌៀប

*ដើមបណ្តឹងរដ្ឋប្បវេណី ខេត្តកំពង់ចាម*

អ្នកស្រី ជា ឌៀប អាយុ៦១ឆ្នាំ កើតក្នុងឆ្នាំ ១៩៥៤។ គាត់រៀបការ និងមានកូនទាំងអស់ចំនួន ៤ នាក់ ហើយបច្ចុប្បន្នរស់នៅខេត្តកំពង់ចាម។ អ្នកស្រី ជា ឌៀប មានបងប្អូនទាំងអស់ ៧ នាក់ប៉ុន្តែ ៤ នាក់ត្រូវខ្មែរក្រហមសម្លាប់។

ឆ្នាំ ១៩៧៦ អ្នកស្រីត្រូវពួកខ្មែរក្រហមគំរាមជាច្រើនលើក និងបង្ខំឱ្យរៀបការ។ ការរៀបការជាក្រុមត្រូវបានរៀបចំឡើងដោយពួកខ្មែរក្រហម ដោយមានទាំងអស់ចំនួន ១២គូ ហើយបុរសៗសុទ្ធតែជាជនពិការ ក្នុងនោះមានទាំងប្តីរបស់អ្នកស្រី ជា ឌៀប ផងដែរ។ អ្នកស្រី ជា ឌៀប មិនបានដឹងពីមូលហេតុដែលគេរៀបចំឱ្យរៀបការជាមួយបុរសសុទ្ធតែជាជនពិការនោះទេ។ អ្នកស្រីបានរំលឹកថា “ខ្ញុំមានអារម្មណ៍ខ្មាស់អៀនជាខ្លាំង ព្រោះតែការរៀបការដោយបង្ខំ ប្រឆាំងនឹងឆន្ទៈខ្ញុំ ហើយជាពិធីរៀបការគ្មានការចូលរួមពីសាច់ញាតិ ឬឪពុកម្តាយទាំងអស់។ យើងត្រូវគេចាប់ផ្គុំជាគូដូចសត្វមាន់ យើងមិនដែលធ្លាប់ជួបមុខគ្នា ប៉ុន្តែយើងសុទ្ធតែគ្មានជម្រើសនឹងប្រកែកឡើយ”។

អ្នកស្រី ជា ឌៀប បង្កើតបានកូនស្រីដំបូងក្នុងឆ្នាំ ១៩៧៩ ប៉ុន្តែកូនរបស់គាត់បានស្លាប់តែរយៈពេលពីរបីខែក្រោយសំរាល ដោយជំងឺគ្រុនក្តៅ និងគ្មានថ្នាំព្យាបាល។ អ្នកស្រី មិនមានពេលវេលាគ្រប់គ្រាន់ក្នុងការបីបាច់ថែទាំសុខភាពខ្លួន និងកូនបន្ទាប់ពីសម្រាលនោះទេ ព្រោះពួកខ្មែរក្រហមបង្ខំឱ្យធ្វើការអំឡុងពេលសសៃខ្ទី ហើយក្រោយមកត្រូវផ្លាស់មករស់នៅខេត្តកំពង់ឆ្នាំង។ ដោយសារតែកង្វះការថែទាំសុខភាពជំនាន់នោះ បច្ចុប្បន្នអ្នកស្រី ជា ឌៀប មានជំងឺឈឺរ៉ាំរ៉ៃ នឹងត្រូវលេបថ្នាំបំបាត់ការឈឺចាប់ជាប្រចាំ នេះដោយសារតែក្រោយសំរាលកូន អ្នកស្រីត្រូវពួកខ្មែរក្រហមបង្ខំឱ្យធ្វើការងារទាំងសរសៃខ្ទី។

*“ខ្ញុំមានអារម្មណ៍ខ្មាស់អៀនជាខ្លាំង ព្រោះតែការរៀបការដោយបង្ខំ ប្រឆាំងនឹងឆន្ទៈខ្ញុំ ហើយជាពិធីរៀបការគ្មានការចូលរួមពីសាច់ញាតិ ឬឪពុកម្តាយទាំងអស់។ យើងត្រូវគេចាប់ផ្គុំជាគូដូចសត្វមាន់ យើងមិនដែលធ្លាប់ជួបមុខគ្នា ប៉ុន្តែយើងសុទ្ធតែគ្មានជម្រើសនឹងប្រកែកឡើយ”*

ដកស្រង់៖ ប្រវត្តិផ្ទាល់មាត់របស់អ្នកស្រី ជា ឡៀប

ដើមបណ្តឹងរដ្ឋប្បវេណី ខេត្តកំពង់ចាម



យប់ដំបូងនៃការរៀបការដោយបង្ខំក្នុងរបបខ្មែរក្រហម
គូរដោយៈ លោក ឱក ប៊ុណ្ណារ័ត្ន

....បន្ទាប់ពីប្តេជ្ញារួចយើងទៅនៅផ្ទះជាមួយគ្នា តែយប់ទីមួយ
ខ្ញុំមិនបានយល់ព្រមរួមរស់ជាមួយគាត់ទេ ហើយខ្ញុំបានសុំអង្វរ
កុំអោយគេធ្វើបាបខ្ញុំ។ នៅយប់នោះគេមិនបានចាប់បង្ខំខ្ញុំទេ
តែមានពួកឈ្លបគេដើរស៊ើបការព្រោះគេចង់ដឹងថាមានអ្នកណា
ប្រឆាំងចំពោះការរៀបចំរបស់អង្គការឬយ៉ាងណា.....

ដកស្រង់៖ ប្រវត្តិផ្ទាល់មាត់របស់អ្នកស្រី ប៉ែន សុខចាន់
ដើមបណ្តឹងរដ្ឋប្បវេណី ខេត្តពោធិ៍សាត់



## ៤.៣.២ អ្នកស្រី មុំ សុវណ្ណា

*ដើមបណ្តឹងរដ្ឋប្បវេណី ខេត្តកំពង់ធំ*

នៅក្នុងឆ្នាំ ១៩៧៨ ប្រធានភូមិបានប្រាប់ថា មិត្តវ៉ាន់ មានគេស្នើរ ខ្ញុំនិយាយថា សម្រេចលើម៉ែ តែប្រធានភូមិថា សម័យនេះសម្រេចលើអង្គការ មិត្តឯងមិនចាំបាច់ប្រកែកទេ បើមិនព្រមគេយកទៅនៅភូមិថ្មី នៅទីនោះមានតែស្លាប់ទេ។ ដល់ថ្ងៃគេក៏មកហៅម្តងទៀត ខ្ញុំថាហេតុអីក៏លឿនម្លេះ? ពេលនោះឈ្លបបាននិយាយសម្លុតថា មិត្តឯងប្រកែកច្រើនដងហើយ ភ្លាមនោះវាបាញ់បញ្ឆិតៗជើងខ្ញុំ ខ្ញុំភ័យញ័រទទ្រើតដើរតាមវាទៅ។

ពេលទៅដល់សហករណ៍បុរសជាគូនឹងខ្ញុំបានចាប់ដៃខ្ញុំប្តេជ្ញាចិត្តថា ទទួលយកមិត្តវ៉ាន់ ជាគូរអនាគតរហូតចាស់ព្រេងចាស់ព្រឹទ្ធ។ ក្រោយពីរៀបការគ្រួសាររួច ខ្ញុំបានលួចរត់ទៅផ្ទះម្តាយ ប្តីខ្ញុំបានទៅតាម ខ្ញុំនិយាយថាទាល់តែសែនម្តងទៀតទើបខ្ញុំព្រម ម្តាយខ្ញុំទៅសុំអង្ករមេភូមិសែនកូនស្រីម្តងទៀត មេភូមិព្រម តែមិនឱ្យពួកឈ្លបដឹងទេ។ ចាប់ពីពេលនោះមកខ្ញុំព្រមរស់នៅជាមួយប្តី មិនយូរប៉ុន្មានខ្ញុំមានផ្ទៃពោះ។ ក្នុងអំឡុងមានផ្ទៃពោះ គេឱ្យកាប់ដំបូក ធ្វើជី កាប់ព្រៃ ច្រូតស្រូវនៅតំបន់ឆ្ងាយៗ ហូបតែបបររាវគេប្រើរហូតដល់កើតកូន កើតកូនបានមួយអាទិត្យ គេឱ្យដេរស្លឹកនិងក្រងស្បូវហាលភ្លៀង ពេលនោះដៃរខ្ញុំ ទាស់រងាញាក់ ព្រឺឆ្អឹងខ្នង ស្ពឹកដៃ ស្ពឹកជើង។ បច្ចុប្បន្ននេះជីវភាពខ្ញុំបានធូរធារ ក្រុមគ្រួសារកូនចៅក៏មានសេចក្តីសុខ។ ឥឡូវនេះ ខ្ញុំមានចៅ១០នាក់ហើយក្នុងនោះមាន ស្រី ៤នាក់ និងប្រុស ៦នាក់។

“...ក្នុងអំឡុងមានផ្ទៃពោះ គេឱ្យកាប់ដំបូក ធ្វើដី កាប់ព្រៃ ច្រូតស្រូវនៅតំបន់ឆ្ងាយៗ ហូបតែបបររាវ គេប្រើរហូតដល់កើតកូន...”

ដកស្រង់៖ ប្រវត្តិផ្ទាល់មាត់របស់អ្នកស្រី មុំ សុវណ្ណា
ដើមបណ្តឹងរដ្ឋប្បវេណី ខេត្តកំពង់ធំ



## ៤.៣.៣ អ្នកស្រី សំ យ៉ាន ដើមបណ្ដឹងរដ្ឋប្បវេណី ខេត្តពោធិ៍សាត់

“...គេឱ្យខ្ញុំនិងស្ត្រីដទៃទៀតធ្វើការអំឡុងពេលមានផ្ទៃពោះដោយឱ្យប្រមូល និងរំកិលដុំសំឡីដែលមានទម្ងន់ប្រហែលជា ២០០ ទៅ ៣០០ គីឡូក្នុងមួយដុំៗ នៅរោងចក្រតម្បាញចិនមួយក្នុងខេត្តបាត់ដំបង...”

ស្ត្រី និងសំពាធការងារអំឡុងពេលមានផ្ទៃពោះ
គូរដោយ៖ លោក ឱក ប៊ុណ្ណារ័ត្ន



## ៤.៣.៤ អ្នកស្រី ហែម ពៅ ដើមបណ្ដឹងរដ្ឋប្បវេណី ខេត្តកំពង់ស្ពឺ

“...ប្ដីខ្ញុំត្រូវអង្គការចោទថាជាខ្មាំងហើយសម្លាប់ចោលក្នុងរបបនោះ....
គេបង្ខំឱ្យខ្ញុំធ្វើការពេលមានផ្ទៃពោះ៨ខែ ឱ្យកាប់ដើមរកាដែលមានទំហំស្មើរ
ប៉ុននឹងពាងទឹកឱ្យបាន៣ដើមក្នុងមួយថ្ងៃដើម្បីរានដីទុកដាំពោត...”

ស្ត្រី និងសំពាធការងារអំឡុងពេលមានផ្ទៃពោះ
គូរដោយ៖ លោក ឱក ប៊ុណ្ណារ័ត្ន

## ៤.៣.៥ អ្នកស្រី យ៉ែម រេ

*ដើមបណ្ដឹងរដ្ឋប្បវេណី - ខេត្តកំពង់ធំ*



នៅក្នុងឆ្នាំ ១៩៧៨ ពួកខ្មែរក្រហមបង្ខំឱ្យខ្ញុំរៀបការជាមួយមិត្ត អឺវ ហើយប្ដេជ្ញាស្រលាញ់គ្នា។ ពួកខ្មែរក្រហមបង្ខំឱ្យធ្វើការដោយដៃទាំងពីរ ដក ស្ទូង កាប់ដំបូករើសលាមកសត្វ លាមកមនុស្ស មកលាយជាមួយកន្ទ្រាងខែត្រធ្វើជាជី។ ខ្ញុំកាន់លាមកពេញៗដៃ ហើយគ្មានពេលសម្រាកទេ អំឡុងពេលខ្ញុំមានផ្ទៃពោះ។ ខ្ញុំចាប់ផ្ដើមចាញ់កូន ខ្ពើម រអើម លាមក ខ្ញុំក្អួត ហើយខ្ញុំសំងំដេក ខ្ញុំហូបមិនបាន ខ្លួនប្រាណស្លេកស្លាំងអស់កម្លាំងខ្ញុំឃ្លាន ហើយពួកខ្មែរក្រហមបានហៅខ្ញុំទៅកសាងដោយចោទថា ជាពួកសក្ដិភូមិនាយទុន និងគំរាមថាមិនស្មោះត្រង់នឹងអង្គការឈឺសតិអារម្មណ៍។ ខ្ញុំខ្លាចពួកគេយកខ្ញុំទៅសម្លាប់ ខ្ញុំគិតម្ដងហើយម្ដងទៀត ខ្វល់ខ្វាយពីអាយុជីវិតខ្ញុំ។ ព្រឹត្តិការណ៍ដ៏ឈឺចាប់នេះបានបន្សល់ទុកឱ្យខ្ញុំឆាប់ភ័យខ្លាចងាយតក់ស្លុត ខ្ញុំឈឺជើង និងស្ពឹកមួយចំហៀងខ្លួន។ រឿងរ៉ាវទាំងនេះបានបន្សល់ឱ្យខ្ញុំនូវការឈឺចាប់ទាំងផ្លូវកាយ និងផ្លូវចិត្តរហូតដល់សព្វថ្ងៃនេះ។

*“...ខ្ញុំឆាប់ភ័យខ្លាច ងាយតក់ស្លុត...រឿងរ៉ាវទាំងនេះបន្សល់ទុកឱ្យ
ខ្ញុំនូវការឈឺចាប់ទាំងផ្លូវកាយ និងផ្លូវចិត្តរហូតដល់សព្វថ្ងៃ...”*

*ដកស្រង់៖ ប្រវត្តិផ្ទាល់មាត់របស់អ្នកស្រី យ៉ែម វេ
ដើមបណ្ដឹងរដ្ឋប្បវេណី ខេត្តកំពង់ធំ*



## ៤.៣.៦ លោក យស់ ផល

*ដើមបណ្តឹងរដ្ឋប្បវេណី - ខេត្តតាកែវ*

នៅក្នុងឆ្នាំ ១៩៧៨ ប្រធានកងបានសួរខ្ញុំថា “បងអាយុច្រើនហើយ អង្គការគិតចង់ឱ្យបងមានប្រពន្ធ តើបងចង់បានប្រពន្ធទេ?” ខ្ញុំឆ្លើយថា “ចង់បាន” ។ គេសួរខ្ញុំទៀតថា “មានគូដណ្តឹងអត់?” ខ្ញុំក៏ប្រាប់ថា “ខ្ញុំមានហើយ”។ គេបន្តសួរទៀតថា “គូរដណ្តឹងមានពាក់ព័ន្ធនឹងអង្គការកម្ទេចទេ?” ខ្ញុំបានប្រាប់ត្រង់ថា នាងមានបងប្រុសម្នាក់ត្រូវបានអង្គការកម្ទេចហើយ គេក៏ថា “បងឯងស្រលាញ់នាងមិនបានទេ ព្រោះថ្ងៃក្រោយគេនឹងកម្ទេចទាំងបងទៀត។ ព្រមធ្វើជាកូនអង្គការទេ ! បើមិនព្រមទៅធ្វើជាយុវជនរហូតទៅ”។ ពេលនោះខ្ញុំបានសម្រេចចិត្តធ្វើជាកូនអង្គការព្រោះខ្ញុំមិនចង់នៅកងចល័តទេ វាលំបាកវេទនាខ្លាំងណាស់ ព្រោះមួយថ្ងៃៗត្រូវគេបង្ខំឱ្យធ្វើការទាំងយប់ ដេកដី ហូបមិនគ្រប់គ្រាន់។ ដើម្បីពិសោធន៍ចិត្តមុននឹងរៀបការ មានយប់មួយនោះមេកងបានប្រកាសថា “បើយុវជនណាហ៊ានញញឹមឆ្លងឆ្លើយដាក់មិត្តនារី អង្គការនឹងយកទៅសម្លាប់ចោល”។ ស្អែកឡើង អង្គការបានរៀបចំឱ្យបុរស ១០នាក់ និងនារី១០ នាក់ឱ្យធ្វើការជាមួយគ្នា។ ខ្ញុំគិតតែធ្វើការ មិនហ៊ានមើលមុខមិត្តនារីណាទេ ព្រោះខ្លាចគេសម្លាប់ចោល។ នៅដើមរដូវវស្សា ម៉ោង១០យប់ ឈ្លបខ្មែរក្រហមបានមកដាស់ខ្ញុំដែលកំពុងដេកក្នុងរោងឱ្យក្រោកឡើង ដោយប្រាប់ថា “ប្រធានកងចល័តស្រុកឱ្យហៅទៅរៀបការ ខ្ញុំសួរថា “ឱ្យខ្ញុំរៀបការជាមួយនរណាគេ?” គេប្រាប់ថា “អត់ដឹងទេ បងឯងទៅនឹងដឹងហើយ”។ ពេលទៅដល់កន្លែងរៀបការនៅភូមិព្រៃរំពាក់ ស្រុកទ្រាំង មេកងបានឱ្យខ្ញុំទៅអង្គុយមុខគេ តែខ្ញុំបានសុំគេអង្គុយក្រោយវិញ ហើយគេក៏ប្រាប់ឱ្យមិត្តនារីមកអង្គុយទន្ទឹមគ្នានឹងបុរស បន្ទាប់មកគេឱ្យគូរៀបការនីមួយៗឡើងប្តេជ្ញាចិត្តរៀបការ។ ចំពោះខ្ញុំការរៀបការដោយបង្ខំ វាប្រៀបបានទៅនឹងការខ្វេះបេះដូងចេញពីទ្រូងអញ្ចឹងគឺ ឈឺចាប់រកអ្វីមកប្រដូចមិនបានទេ។

“...ការរៀបការដោយបង្ខំចំពោះខ្ញុំ វាប្រៀបបាននឹងការខ្វេះ
បេះដូងចេញពីដើមទ្រូង...វាឈឺចាប់និងប៉ះផ្លូវចិត្តណាស់ ហើយយើង
គួរតែចែករំលែករឿងរ៉ាវទាំងនេះឱ្យអ្នកជំនាន់ក្រោយបានដឹង...”

ដកស្រង់៖ ប្រវត្តិផ្ទាល់មាត់របស់លោក យស់ ផល
ដើមបណ្ដឹងរដ្ឋប្បវេណី ខេត្តតាកែវ



## ៤.៣.៧ អ្នកស្រី ប៉ែន សុខចាន់

*ដើមបណ្ដឹងរដ្ឋប្បវេណី ខេត្តពោធិ៍សាត់*

១៩៧៨ ខ្ញុំត្រូវបានមេកង ឈ្មោះ ពូ អឿន បង្ខំឱ្យរៀបការដោយមានចំនួន១២គូដែលត្រូវឡើងប្ដេជ្ញាចិត្តដោយខ្ញុំមិនបានដឹងមុនទេ។ មនុស្សប្រុសស្រីត្រូវគេរៀបចំឱ្យអង្គុយមួយជួរៗ ហើយគេចែកសំពត់ អាវខ្មៅ និងក្រមាថ្មីមួយឱ្យយកទៅស្លៀកពាក់រួចចេញមកអង្គុយទល់មុខគ្នា។ គូដែលគេរៀបឱ្យខ្ញុំឈ្មោះ តក់ សាត មានអាយុ២៥ឆ្នាំ ចំណែកខ្ញុំគឺទើបតែមានអាយុ១៦ឆ្នាំទេ។ បន្ទាប់ពីប្ដេជ្ញារួចយើងទៅនៅផ្ទះជាមួយគ្នា តែយប់ទីមួយខ្ញុំមិនបានយល់ព្រមរួមរស់ជាមួយគាត់ទេ ហើយខ្ញុំបានសុំអង្វរ កុំឱ្យគេធ្វើបាបខ្ញុំ នៅយប់នោះគេមិនបានចាប់បង្ខំខ្ញុំទេ តែមានពួកឈ្លបគេដើរស៊ើបការព្រោះគេចង់ដឹងថាមានអ្នកណាប្រឆាំងចំពោះការរៀបចំរបស់អង្គការឬយ៉ាងណា។ ស្រាប់តែយប់ទីពីរ គេបានហៅប្ដីខ្ញុំទៅប្រជុំ បន្ទាប់ពីត្រឡប់មកវិញគេក៏បានចាប់បង្ខំខ្ញុំ ដោយចាប់ទះកំភ្លៀងពេលខ្ញុំប្រកែកជាមួយគេ ហើយព្យាយាមចាប់បង្ខំខ្ញុំ តែខ្ញុំព្យាយាមរត់ទៅរកពូរបស់ខ្ញុំដែលនៅជិតនោះឱ្យជួយ។ យប់ទីបីនោះគេបានហៅគាត់ទៅប្រជុំទៀតដោយលើកនេះខ្ញុំមិនអាចគេចរួចនោះទេ ព្រោះគេបានចាប់បង្ខំខ្ញុំដោយប្រើកំលាំងបាយ គេបានចាប់ដៃខ្ញុំចងហើយរំលោភខ្ញុំរហូតបានសម្រេច បើទោះជាខ្ញុំព្យាយាមគេច ម្យ៉ាងទៀតមានពួកឈ្លបបានចាំមើលនៅខាងក្រោមផ្ទះ ហើយបើសិនជាខ្ញុំនៅតែមិនព្រមទៀតនោះគេច្បាស់ជាយកខ្ញុំទៅសម្លាប់ចោលជាមិនខាន។

ខ្ញុំមានអារម្មណ៍ថា ខ្ញុំតូចចិត្តនឹងជីវិតណាស់ សព្វថ្ងៃគឺសង្គមស្អប់ខ្ពើមខ្ញុំ ដោយគេមិនឱ្យកូនប្រុសគេស្រលាញ់កូនស្រីរបស់ខ្ញុំទេ ព្រោះខ្ញុំគ្មានខាន់ស្លាដោយបានរៀបការក្នុងសម័យខ្មែរក្រហម។ សព្វថ្ងៃខ្ញុំនៅតែខឹងនឹងខ្លួនឯង តូចចិត្ត ឈឺក្បាល ដេកមិនលក់ ញ័រសាច់ និងមិនឃ្លានអាហារ ហើយ ខ្ញុំពិតជាចង់ឱ្យក្មេងជំនាន់ក្រោយដឹងនូវរឿងរ៉ាវទាំងអស់របស់ខ្ញុំ។

*"... ខ្ញុំមានអារម្មណ៍ថា ខ្ញុំតូចចិត្តនឹងជីវិតណាស់ សព្វថ្ងៃគឺសង្គមស្អប់ខ្ពើមខ្ញុំ ដោយគេមិនឱ្យកូនប្រុសគេស្រលាញ់កូនស្រីរបស់ខ្ញុំទេ ព្រោះខ្ញុំគ្មានខាន់ស្លាដោយបានរៀបការក្នុងសម័យខ្មែរក្រហម... ខ្ញុំពិតជាចង់ឱ្យក្មេងជំនាន់ក្រោយដឹងនូវរឿងរ៉ាវទាំងអស់របស់ខ្ញុំ..."*

ដកស្រង់៖ ប្រវត្តិផ្ទាល់មាត់របស់អ្នកស្រី ប៉ែន សុខចាន់
ដើមបណ្ដឹងរដ្ឋប្បវេណី ខេត្តពោធិ៍សាត់



## ៤.៣.៨ អ្នកស្រី ស៊ូ សុធារី

*ដើមបណ្ដឹងរដ្ឋប្បវេណី ខេត្តតាកែវ*

គេបង្ខំឱ្យខ្ញុំរៀបការជាមួយនារីម្នាក់ដែលខ្ញុំមិនដែលស្រលាញ់ទាល់តែសោះ ហើយគេបានអនុញ្ញាតឱ្យយើងជួបមុខគ្នារយៈពេល ១០ ថ្ងៃម្ដង។ នៅពេលនោះខ្ញុំបានបាក់ចិត្តស្រលាញ់បុរសម្នាក់ទៀត។ ខ្ញុំរស់នៅក្នុងផ្ទះជាមួយគ្នាដូចប្ដីប្រពន្ធ ខ្ញុំជាប្រជាជនថ្មី ប៉ុន្តែ ស៊ិន ជាប្រជាជនចាស់។ ប្រហែលជាខ្មែរក្រហមដឹងថា ខ្ញុំជាមនុស្សភេទទីបី ព្រោះមានថ្ងៃមួយមានទាហានខ្មែរក្រហមប្រហែល ប្រាំពីរ ឬប្រាំបីនាក់បានមកហៅខ្ញុំពេលខ្ញុំកំពុងរើសថ្មលើភ្នំ ហើយពួកវាបានរំលោភខ្ញុំយ៉ាងព្រៃផ្សៃបំផុត។

ពេលនោះខ្ញុំសន្លប់បាត់ស្មារតី ហើយពេលដែលខ្ញុំដឹងខ្លួនរាងកាយខ្ញុំប្រឡាក់សុទ្ធតែឈាម។ ខ្ញុំវារដោយដៃ និងជង្គង់ត្រលប់មកផ្ទះវិញ ហើយប្រាប់ ស៊ិន ពីអ្វីដែលបានកើតឡើង។ ថ្ងៃនោះគាត់នៅផ្ទះកំពុងត្បាញបង្គី។ គាត់អោបខ្ញុំ ហើយយើងទាំងពីរអ្នកយំជាមួយគ្នា។ នៅពេលយប់នោះ យើងចាប់ផ្ដើមជជែកគ្នាដើម្បីរកវិធីគេច។ ខ្ញុំបានដាក់ពាក្យបណ្ដឹងស្ដីពីការរំលោភហិង្សាផ្លូវភេទ និងសិទ្ធិមនុស្ស។ ជនរងគ្រោះភេទទីបីជាច្រើននាក់ មិនចង់ចូលរួមដាក់ពាក្យបណ្ដឹងនោះទេ។ ពួកគេនិយាយថា ជីវិតយើងរាល់ថ្ងៃនេះមិនអាចទទួលបានការឱ្យតម្លៃ និងយុត្តិធម៌ផង ចុះធ្វើម៉េចនឹងតុលាការអាចរកយុត្តិធម៌ឱ្យយើងបាននោះ។

ខ្ញុំចង់ឱ្យពិភពលោកបានដឹងថា ពួកខ្មែរក្រហមជាឧក្រិដ្ឋជនប្រល័យពូជសាសន៍នៅក្នុងប្រទេសមួយនេះ ហើយចង់ឱ្យពិភពលោកបានដឹងពីអ្វីដែលបានកើតឡើងក្នុងប្រទេសកម្ពុជា។ ខ្ញុំមានអារម្មណ៍ធូរស្រាលនៅពេលដែលបាននិយាយរឿងនេះ ដូច្នេះរូបភាព និងព័ត៌មានរបស់ខ្ញុំប្រហែលជាអាចនឹងក្លាយទៅជាការជំរុញទឹកចិត្តដល់អ្នកផ្សេងទៀត។ ដូចជាសក្ខីកម្មរបស់ខ្ញុំ វាបានជំរុញទឹកចិត្តខ្ញុំ ព្រោះវាមិនមែនសម្រាប់តែខ្ញុំម្នាក់ឯងទេ តែក៏ដើម្បីផ្ដល់ជាកម្លាំងចិត្តអ្នកដ៏ទៃផងដែរ។

“...ខ្ញុំមានអារម្មណ៍ធូរស្រាលនៅពេលដែលបាននិយាយរឿងនេះ ដូច្នេះរូបភាព
និងព័ត៌មានរបស់ខ្ញុំប្រហែលជាអាចនឹងក្លាយទៅជាការជំរុញទឹកចិត្តដល់អ្នកផ្សេងទៀត...”

ដកស្រង់៖ ប្រវត្តិផ្ទាល់មាត់របស់អ្នកស្រី ស៊្វ សុធារី
ដើមបណ្ដឹងរដ្ឋប្បវេណី ខេត្តតាកែវ



## ៥. ព័ត៌មានអំពីអ្នករៀបចំគម្រោង និងអង្គការដៃគូ

អង្គភាពគាំពារជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) សហការជាមួយអង្គការចិត្តសង្គមអន្តរវប្បធម៌កម្ពុជា (ធីភីអូ) បាននឹងកំពុងអនុវត្តគម្រោងដំណាក់កាលទី២ដែលមានឈ្មោះថា "ការលើកកម្ពស់សមភាពយេនឌ័រ និងការធ្វើឱ្យប្រសើរឡើងលើលទ្ធភាពទទួលបានយុត្តិធម៌ដល់ដើមបណ្តឹងរដ្ឋប្បវេណីស្ត្រី និងជនរងគ្រោះដោយហិង្សាផ្លូវភេទក្នុងសម័យខ្មែរក្រហម" ដែលមានរយៈពេលបីឆ្នាំចាប់ពីខែមករា ឆ្នាំ២០១៦ ក្រោមកម្មវិធីវិធានការនានាក្រៅបច្ចេកទេសតុលាការនៃ អ.វ.ត.ក។ សកម្មភាពក្នុងគម្រោងដំណាក់កាលទី២ រួមមាន ការផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការយល់ដឹងពីយេនឌ័រ ពិព័រណ៍ចល័ត វេទិកាសាធារណៈ កម្មវិធីវិទ្យុ ផ្តល់វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ការចូលរួមរបស់ដើមបណ្តឹងនៅក្នុងសវនាការ កម្មវិធីផ្សព្វផ្សាយពីហិង្សាប្រឆាំងនឹងស្ត្រីក្នុងរបបខ្មែរក្រហម និងការផ្តល់សេវាគាំទ្រផ្លូវចិត្តដល់ដើមបណ្តឹងតាមបណ្តាខេត្តនានាក្នុងប្រទេសកម្ពុជា។

គម្រោងនេះត្រូវបានអនុវត្តម្តងរួចមកហើយក្នុងដំណាក់កាលទី ១ ដែលមានរយៈពេលបីឆ្នាំគឺ ចាប់ផ្តើមនៅចុងឆ្នាំ ២០១១ ដល់ ២០១៤ និងអនុវត្តសកម្មភាពដោយអង្គការដៃគូរចំនួនបីគឺ អង្គភាពគាំពារជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) អង្គការចិត្តសង្គមអន្តរវប្បធម៌កម្ពុជា (ធីភីអូ)និងអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិមនុស្ស (ស៊ីឌីភី)។

## អង្គភាពគាំពារជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)

អង្គភាពគាំពារជនរងគ្រោះ ត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៨ ដើម្បីធានាឱ្យមានការចូលរួមរបស់ជនរងគ្រោះក្នុងកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក ប្រកបដោយអត្ថន័យ។ ភារកិច្ចទាំងនេះរួមមាន ១) សម្របសម្រួលដល់ការចូលរួមរបស់ជនរងគ្រោះនៅក្នុងកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក និង ២) កំណត់ សម្របសម្រួល និងអនុវត្តគម្រោងសំណង ទាំងជាវិធានការតុលាការ និងមិនមែនតុលាការ ដើម្បីបម្រើផលប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក ក៏ដូចជាដល់ជនរងគ្រោះនៃ របបខ្មែរក្រហមជាទូទៅផងដែរ។

អាសយដ្ឋាន៖ ផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ
ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ប្រអប់សំបុត្រ ៧១
ភ្នំពេញ កម្ពុជា

លេខទូរស័ព្ទ៖ ០២៣ ៨៦១ ៨៤៣/០២៣ ៨៦០ ២០៣

ព័ត៌មានបន្ថែមស្តីពីហិង្សាយេនឌ័រក្នុងរបបខ្មែរក្រហម
សូមចូលទៅកាន់៖

គេហទំព័រ៖ http://gbvkr.org/

បណ្តាញទំនាក់ទំនងសង្គម(Facebook)៖ Gender based violence under the Khmer Rouge

## អង្គការចិត្តសង្គមអន្តរវប្បធម៌កម្ពុជា“ធីភីអូ”

អង្គការចិត្តសង្គមអន្តរវប្បធម៌កម្ពុជា ហៅកាត់ថា (ធីភីអូ) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៥។ ធីភីអូ  ជាអង្គការផ្នែកចិត្តសង្គមតែមួយគត់នៅក្នុងប្រទេសកម្ពុជា ដែលបានចូលរួម ចំណែកក្នុងដំណើរការ យុត្តិធម៌អន្តរកាលក្នុងបរិបទនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក)  តាមរយៈ ការផ្តល់សេវាសុខភាពផ្លូវចិត្តយ៉ាងទូលំទូលាយដល់ ដើមបណ្តឹងរដ្ឋប្បវេណី ក្រោមកិច្ចចុះហត្ថលេខាលើ អនុស្សរណៈយោគយល់ ចាប់តាំងពីឆ្នាំ២០០៧។ សេវាកម្មទាំងនេះមានចាប់តាំងពីការគាំទ្រនៅនឹងកន្លែងនៅសាលាក្តីខ្មែរក្រហមការព្យាបាលការប៉ះទង្គិចផ្លូវចិត្តដែលមានលក្ខណៈបែបវប្បធម៌ សាសនា និងក្រុមជួយខ្លួនឯង រហូតដល់សកម្មភាពនៃការប្រាប់ការពិត ការផ្សះផ្សា វគ្គបណ្តុះបណ្តាលជនបង្គោល ការអប់រំផ្សព្វផ្សាយ និងគម្រោងសិក្សាស្រាវជ្រាវ។

អាសយដ្ឋាន៖ អគារលេខ ២&៤ ផ្លូវហាណូយ កែងផ្លូវឧកញ៉ាវាំង
សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ

លេខទូរស័ព្ទ៖ ០២៣ ៦៣៦៦ ៩៩២

អ៊ីម៉ែល៖ admin@tpocambodia.org

គេហទំព័រ៖ www.tpocambodia.org

# ៦. អង្គការដែលធ្វើការក្នុងបរិបទហិង្សាយេនឌ័រក្នុងរបបខ្មែរក្រហម

## *ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា* (CDP)

ផ្ទះលេខ បេ៩ហ្សិដ ផ្លូវសឡា សង្កាត់ស្ទឹងមានជ័យ ខ័ណ្ឌមានជ័យ
លេខទូរស័ព្ទ៖ ០២៣ ៩០០ ៦២០

## *អង្គការក្ដីករុណា* (KdK)

ផ្ទះ ៦៩ វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
លេខទូរស័ព្ទ៖ ០២៣ ៦៩៥ ៦៤ ១២
សារអេឡិចត្រូនិច៖ info@kdei-karuna.org
គេហទំព័រ៖ www.kdei-karuna.org

## *មជ្ឈមណ្ឌលធនធានសោតទស្សន៍បុប្ផាណា* (Bophana)

ផ្ទះលេខ ៦៤ ផ្លូវលេខ ២០០ ឧកញ៉ាម៉ែន សង្កាត់បឹងរាំង ខណ្ឌដូនពេញ ភ្នំពេញ ១២២១១ កម្ពុជា
លេខទូរស័ព្ទ៖ ០២៣ ៩៩២ ១៧៤
សារអេឡិចត្រូនិច៖ info@bophana.org និង archives@bophana.org
គេហទំព័រ៖ www.bophana.org

## *សាលាសិល្បៈខ្មែរ* (KAA)

ផ្ទះលេខ ១៣៥ ផ្លូវ ១១៥ ក្រុងតាខ្មៅ រាជធានីភ្នំពេញ
លេខទូរស័ព្ទ៖ ០២៣ ៤២៥ ៧៨០
សារអេឡិចត្រូនិច៖ info@khmerarts.org
គេហទំព័រ៖ www.khmerarts.org

*អង្គការយុវសន្តិភាព* (YFP)

ផ្ទះលេខ ៤-៦G ផ្លូវ ៥១៣ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កម្ពុជា
លេខទូរស័ព្ទ៖ +៨៥៥ ២៣ ៨៨១ ៣៤៦/ ៩៩ ១៣ ៤៦
សារអេឡិចត្រូនិច៖ admin@yfpcambodia.org
គេហទំព័រ៖ www.yfpcambodia.org

## ៧. ឯកសារយោង

១. រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)

២. សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងប្រកាសនៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ សំណុំរឿងលេខ០០២/០១

៣. ដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០២

៤. គេហទំព័រ៖ www.eccc.gov.kh

៥. គេហទំព័រ៖ www.gbvkr.org




អនុវត្តគម្រោងដោយ

អង្គភាពគាំពារជនរងគ្រោះ
នៃ អ.វ.ត.ក

សហការជាមួយ

កម្មវិធីសុខភាពផ្លូវចិត្ត
TPO
អង្គការចិត្តសង្គម អន្តរវប្បធម៌
Transcultural Psychosocial Organization
Community Mental Health Programme

អង្គការ ធីភីអូ កម្ពុជា

ឧបត្ថម្ភដោយ

UNITED NATIONS TRUST FUND
TO END VIOLENCE AGAINST WOMEN

មូលនិធិអង្គការសហប្រជាជាតិ
ដើម្បីលុបបំបាត់អំពើហិង្សាលើស្ត្រី




# FORCED MARRIAGE
# DURING THE KHMER ROUGE REGIME



First Edition

# TABLE OF CONTENTS


Preface by H. E Kranh Tony............................................ 1

Remarks by the Victims Support Section ............................... 2

1. Democratic Kampuchea Regime ........................................ 3

2. Extraordinary Chambers in the Courts of Cambodia (ECCC) 5

2.1. About ECCC.......................................................... 5

2.2. Caseload of the ECCC............................................... 6

2.2.1. Case 001.......................................................... 7

2.2.2. Case 002.......................................................... 8

- Case 002/01...................................................... 11
- Case 002/02...................................................... 12

2.2.3. Case 003 and 004.............................................. 13

3. Forced marriage and rape in the context of forced marriage 14

3.1. What was forced marriage during the Khmer Rouge...... 15

3.2. The number of Civil Parties of forced marriage at the ECCC 19

3.3. Legal representation and psychological support............ 20




*Evacuation in Phnom Penh, 1975*

*Photo source: Roland Neveu*



4. Perspectives among experts and voices of survivors.............................. 21
4.1. Gender based violence during the Khmer Rouge and its impacts......... 22
4.2. Psychological support for victims of gender-based violence.................. 23
4.3. Perspectives and voices among survivors.................................... 24
4.3.1. Mrs. Chea Diep ................................................................. 28
4.3.2. Mrs. Mom Sovann ............................................................. 32
4.3.3. Mrs. Sam Yann ................................................................... 34
4.3.4. Mrs. Hem Pov..................................................................... 35
4.3.5. Mrs. Yem Ve........................................................................ 36
4.3.6. Mr. Yuos Phal ..................................................................... 38
4.3.7. Mrs. Pen Sokchan................................................................ 40
4.3.8. Mrs. Sou Sotheavy.............................................................. 42
5. Information on the organizer and implementing partner........................... 44
6. NGO Partners that work in the context of gender-based violence............... 46
7. References.............................................................................................. 47



*Organized by:* Victims Support Section of the Extraordinary Chambers in the Courts of Cambodia

*Print:* August 2017, Phnom Penh, Cambodia

*Photo cover:* Wedding ceremony of Mr. Noun Houy, alias Houy Sre

*Photo source:* Document Center of Cambodia (DC-Cam)

*Cambodians need to remember the past,
but they also need to live meaningfully
in the present and move proudly
towards a splendid future.*

# PREFACE



